ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៦៨ សជណ ធទឧ

# សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា : សម្ពាធទាបមួយដែលបានកើតឡើងនៅលើប្រទេសឡាវ និងប្រទេសវៀតណាមភាគកណ្តាល កំពុងបន្តមានឥទ្ធិពលលើតំបន់អាងទន្លេមេគង្គ និងព្រះរាជាណាចក្រកម្ពុជា ។

យោងតាមការព្យាករណ៍ បានបង្ហាញថា ឥទ្ធិពលនៃជ្រលងសម្ពាធទាបខាងលើ គួបផ្សំជាមួយនឹងខ្យល់មូសុងនិរតីខ្លាំង នឹងបង្កឱ្យអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា ( ចាប់ពីថ្ងៃទី 02 ដល់ថ្ងៃទី 07 ខែសីហា ឆ្នាំ 2014 ) មានស្ថានភាព ដូចខាងក្រោម :

- **តំបន់ខ្ពង់រាប :** រួមមានខេត្តឧត្តរមានជ័យ ព្រះវិហារ រតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ក្រចេះ កំពង់ចាម និងខេត្តត្បូងឃ្មុំ នឹងបន្តមានភ្លៀងធ្លាក់ច្រើន ។
- **តំបន់ទំនាបកណ្តាល :** រួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប កំពង់ធំ ព្រៃវែង និងខេត្តស្វាយរៀង នឹងមានភ្លៀងធ្លាក់ពីបង្គួរទៅច្រើន ។ ដោយឡែកចំពោះខេត្តកំពង់ស្ពឺ និងខេត្តតាកែវ អាចមានភ្លៀងធ្លាក់ក្នុងកម្រិតមធ្យម ។
- **តំបន់មាត់សមុទ្រ :** រួមមានខេត្តកោះកុង ព្រះសីហនុ កែប និងខេត្តកំពត នឹងមានភ្លៀងបន្តធ្លាក់ច្រើនជោគជាំ រួមជាមួយខ្យល់បក់បោកខ្លាំង ។ ផ្ទៃសមុទ្រអាចនឹងមានខ្យល់ខ្លាំង បង្កើតជារលកក្នុងកំពស់ពី 01 ម៉ែត្រ ទៅ 2,5 ម៉ែត្រ ។

ការបន្តធ្លាក់ភ្លៀងនៅតាមបណ្តាខេត្ត ដូចបានជម្រាបជូនខាងលើ អាចបង្កឱ្យមានជំនន់ទឹកភ្លៀងនៅតំបន់មួយចំនួន ពិសេសតំបន់ទំនាបនៅក្នុងខេត្ត តំបន់ដែលនៅជាប់នឹងផ្លូវទឹក និងកំណាត់ផ្លូវជាតិលេខ 4 ដែលស្ថិតនៅក្នុងភូមិ-សាស្ត្រស្រុកកំពង់សីលា ខេត្តព្រះសីហនុ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន ពិសេសចំពោះបងប្អូនប្រជានេសាទ និងអ្នកធ្វើដំណើរតាមសមុទ្រ សូមបង្កើនការយកចិត្តទុកដាក់ខ្ពស់ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

លឹម គានហោ